# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ....០៤២/១៩....**ក.ប**/**ល.ណ.ន.ខ.ល**

# សេចក្តីណែនាំ

## ស្តីពី

## ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថាន ក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនចំពោះម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ ជ្រាបថា យោងតាមកម្រិតហានិភ័យទាប និងស្ថានភាពជាក់ស្តែងនៃសហគ្រាស គ្រឹះស្ថានក្រៅពីផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ ត្រូវបានពន្យារពេលក្នុងការអនុវត្តទៅខែធ្នូ ឆ្នាំ២០២១ ដោយត្រូវទូទាត់រំលឹកចំនួន ៦ថ្ងៃ ក្នុង១ឆ្នាំ ក្នុងនោះចំនួន ៣ថ្ងៃ នៅក្នុងខែមិថុនា និង ៣ថ្ងៃ នៅក្នុងខែធ្នូ។

ក្នុងអំឡុងពេលនៃការពន្យារការអនុវត្តនេះ កម្មករនិយោជិតណាដែលត្រូវបានបញ្ឈប់ពីការងារដោយមូលហេតុក្រៅពីកំហុសធ្ងន់ ឬចូលនិវត្តន៍ ឬទទួលមរណភាព និយោជកត្រូវបើកផ្តាច់នូវប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារទាំងអស់តែម្តង ជូនកម្មករនិយោជិត ឬទាយាទរបស់កម្មករនិយោជិត។

ចំពោះកម្មករនិយោជិតដែលលាឈប់ពីការងារដោយឯកឯង ឬត្រូវបានបញ្ឈប់ពីការងារដោយកំហុសធ្ងន់ នឹងមិនត្រូវបានទទួលនូវការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ដែលមានមុនឆ្នាំ២០១៩ នោះទេ។

ដោយឡែក និយោជកត្រូវអនុវត្តការទូទាត់ "ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆ្នាំ ដែលមានចាប់ពីឆ្នាំ២០១៩" ស្របតាមខ្លឹមសារប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដោយ ១ឆ្នាំ ត្រូវទូទាត់ជូនកម្មករនិយោជិតចំនួន ១៥ថ្ងៃ និងត្រូវបើក ២ដង ក្នុង១ឆ្នាំ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតទាំងអស់ នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះបានត្រឹមត្រូវ និងធានាបានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ២រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩